**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៨ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើត គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**មាត្រាមួយ .-**

មាត្រា៣ មាត្រា៨ និងមាត្រា៩ នៃអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ **គ.អ.ទ.ស.** ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖



https://www.moj.gov.kh/kh/law-regular

**មាត្រា៣ .- ថ្មី**

**គ.អ.ទ.ស**. មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ទេសរដ្ឋមន្ត្រី ១រូប | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ ១០រូប | សមាជិក |
| - ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្ត | សមាជិក |
| - ប្រធានលេខាធិការដ្ឋាន **គ.អ.ទ.ស**. | សមាជិក។ |



https://www.moj.gov.kh/kh/law-regular

សមាសភាពជាក់ស្តែងនៃ **គ.អ.ទ.ស**. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.អ.ទ.ស**. អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័ន ឬតំណាងនៃក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតនៃរាជរដ្ឋាភិបាល ឬអ្នកជំនាញដែលមានបទពិសោធពាក់ព័ន្ធ តាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៨ .‒ ថ្មី**

**គ.អ.ទ.ស**. មានអង្គភាពមួយនៃក្រសួងទេសចរណ៍ ជាលេខាធិការដ្ឋាន **គ.អ.ទ.ស**. តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.អ.ទ.ស**. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ទ.ស**.។

សមាសភាពជាក់ស្តែងរបស់លេខាធិការដ្ឋាន **គ.អ.ទ.ស**. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ទ.ស**. តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា៩ .‒ ថ្មី**

**គ.អ.ទ.ស**. មានប្រភពធនធានផ្តត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍។

**គ.អ.ទ.ស**. មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់ប្រភពធនធានស្របច្បាប់ផ្សេងៗតាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រាពីរ .‒**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .‒**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular